# សេចក្តីប្រកាសព័ត៌មាន

## សិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តប្រកាស ស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច"

ថ្ងៃអង្គារ ៧រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២

ទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នៅព្រឹកថ្ងៃអង្គារ ៧រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តប្រកាសស្តីពី "**ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច**" នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមដល់សិក្ខាកាមទាំងអស់ អំពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃអចលនវត្ថុក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាសិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនវាយតម្លៃ និងអ្នកជំនាញវាយតម្លៃ សំដៅធានាឱ្យបាននូវសុក្រឹតភាពនៃតម្លៃបរធនបាលកិច្ចដែលបានបង្កើត និងចុះបញ្ជីបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីតំណាងនិយ័តករពាក់ព័ន្ធក្រោមឱវាទ **អ.ស.ហ.** ថ្នាក់ដឹកនាំ និងសមាជិក-សមាជិកាសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា, តំណាងពីសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា, ប្រតិបត្តិករបរធនបាលដែលជាក្រុមហ៊ុនបរធនបាល និងជាបរធនបាលរូបវន្តបុគ្គលឯករាជ្យ, ប្រតិបត្តិករបរធនបាលដែលផ្តល់សេវារក្សាសុវត្ថិភាពនិងសេវារក្សាទុក, តំណាងការិយាល័យមេធាវី និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវានៅក្នុងវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា និងមានអ្នកចូលរួមសរុបចំនួន ១៥៨ រូប។